ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៩ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសិក្សាពីលទ្ធភាព បង្កើតឧទ្យានជាតិសមុទ្រកោះរុង ដែលមានទីតាំងស្ថិតនៅតំបន់កោះរុង ខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ០២/នស/៩៤ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៥៥អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សាពីលទ្ធភាពការបង្កើតឧទ្យានជាតិសមុទ្រកោះរុងដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **សាយ សំអាល់** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| ២-ឯកឧត្តម **គីករ៉េត សំរេច** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |

www.pheakdeylaw.com

| | | |
|---|---|---|
| ៣-ឯកឧត្តម **យិន គិមស៊ាន** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | អនុប្រធាន |
| ៤-ឯកឧត្តម **យន្ត មីន** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | អនុប្រធានអចិន្ត្រៃយ៍ |
| ៥-ឯកឧត្តម **ឌិត ទីណា** | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៦-ឯកឧត្តម **ឥន់ វ៉ាន់ថាវ៉ា** | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៧-ឯកឧត្តម **ឈៅ ឆូក** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨-ឯកឧត្តម **លេខ ទី** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩-ឯកឧត្តម **យស់ ឆោមណារ៉ាឌី** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១០-ឯកឧត្តម **ចាយ សាមិត្ត** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ<br>អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ | សមាជិក |
| ១១-ឯកឧត្តម **ហេង ណាវ៉េត** | អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន | សមាជិក |
| ១២-ឯកឧត្តម **ភាច សុទ្ធី** | អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន | សមាជិក |
| ១៣-ឯកឧត្តម **វ៉ាន់ មុនីនាថ** | អគ្គលេខាធិការរងនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | សមាជិក |
| ១៤-លោក **គឹម ឈុង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ | សមាជិក |
| ១៥-លោក **ថៃ ចន្ថា** | ប្រធាននាយកដ្ឋានអភិរក្សសមុទ្រ និងតំបន់ឆ្នេរ | លេខាធិការ។ |

**ប្រការ ២.-**

គណៈកម្មការអន្តរក្រសួង ដើម្បីសិក្សាពីលទ្ធភាពការបង្កើតឧទ្យានជាតិសមុទ្រកោះរុងមានតួនាទីភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវពីសារៈសំខាន់ខាងផ្នែកជីវៈចម្រុះ សណ្ឋានដី ភូគព្ភសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សេដ្ឋកិច្ច និងសង្គម ដែលជាសក្តានុពលសម្រាប់ការរៀបចំបង្កើតឧទ្យានជាតិសមុទ្រកោះរុង
- សិក្សារៀបចំកំណត់ព្រំប្រទល់ និងធ្វើផែនទីសម្រាប់ការបង្កើតឧទ្យានជាតិសមុទ្រកោះរុង
- សិក្សាវាយតម្លៃ កំណត់ និងបែងចែកតំបន់គ្រប់គ្រងឱ្យស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍នានា ដើម្បីទទួលបានការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់ជំរុញដល់ដំណើរការបង្កើត និងគ្រប់គ្រងឧទ្យានជាតិសមុទ្រកោះរុង
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារ និងរៀបចំសេចក្តីព្រាងអនុក្រឹត្យ ព្រមទាំងលិខិតបទដ្ឋាននានាសម្រាប់ដាក់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចក្នុងការបង្កើតឧទ្យានជាតិសមុទ្រកោះរុង
- ទទួលភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ ៣.-**

គណៈកម្មការអន្តរក្រសួង ដើម្បីសិក្សាពីលទ្ធភាពការបង្កើតឧទ្យានជាតិសមុទ្រកោះរុង មានសិទ្ធិបង្កើតក្រុមការងារជំនាញបច្ចេកទេសអន្តរក្រសួង និងអាចប្រើប្រាស់មន្ត្រីរបស់ស្ថាប័នសាមី ដើម្បីចូលរួមអនុវត្តភារកិច្ចរបស់គណៈកម្មការអន្តរក្រសួង ដូចមានចែងក្នុងការប្រការ២។

**ប្រការ ៤.-**

អនុប្រធាន និងសមាជិកនៃគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សាពីលទ្ធភាពបង្កើតឧទ្យានជាតិសមុទ្រកោះរុងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ ៥.-**

សមាជិកគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សាពីលទ្ធភាពការបង្កើតឧទ្យានជាតិសមុទ្រកោះរុង និងក្រុមការងារជំនាញបច្ចេកទេសអាចប្រើប្រាស់ថវិការបស់ស្ថាប័នសាមី ដើម្បីបំពេញបេសកម្មការងារ។

**ប្រការ ៦.-**

គណៈកម្មការអន្តរក្រសួង ដើម្បីសិក្សាពីលទ្ធភាពការបង្កើតឧទ្យានជាតិសមុទ្រកោះរុង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com